ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ ១០៨១៨ ......អពដ

# សេចក្តីបំភ្លឺ

ថ្មីៗនេះ អគ្គនាយកដ្ឋានពន្ធដារសង្កេតឃើញថា សារព័ត៌មាន ឡារ៉ែន បានចុះផ្សាយអត្ថបទមួយក្រោមចំណងជើងថា "**អគ្គនាយកដ្ឋានពន្ធដារ លែងអនុញ្ញាតឱ្យអាជ្ញាធរក្រុងភ្នំពេញប្រមូលពន្ធស្លាកយីហោនានា**" ដោយបានលើកឡើងថា *ការប្រមូលពន្ធលើស្លាកយីហោអាចធ្វើឡើងបានដោយស្ថាប័នពន្ធដារតែមួយប៉ុណ្ណោះ ហើយសាលារាជធានីភ្នំពេញមិនមានសិទ្ធិប្រមូលពន្ធលើស្លាកយីហោ ឬប្រមូលពន្ធសេវាលើស្លាកយីហោនេះទេ ព្រោះថា ប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនមានចែងអនុញ្ញាតឱ្យសាលាក្រុងត្រូវប្រមូលពន្ធពីវិស័យឯកជនលើការប្រមូលពន្ធស្លាកយីហោឡើយ។*

អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការបំភ្លឺជូនសារព័ត៌មាន ឡារ៉ែន ក៏ដូចជាសាធារណជនទាំងអស់ មេត្តាជ្រាបថា នៅក្នុងកិច្ចប្រជុំពិភាក្សាជាមួយសភាពាណិជ្ជកម្មនាពេលថ្មីៗនេះ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារបានបញ្ជាក់ជូនអង្គប្រជុំយ៉ាងដូច្នេះថា ផ្អែកតាមច្បាប់ស្តីពីការបង្កើតពន្ធតែមប្រិ៍សារពើពន្ធដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ២៣ ក្រ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា និងវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិបន្តបន្ទាប់ ពាក់ព័ន្ធនឹងការប្រមូលពន្ធតែមប្រិ៍សារពើពន្ធ គឺមានចែងអំពីការប្រមូលពន្ធតែមប្រិ៍ ចំពោះផ្ទាំងរូបភាពផ្សាយពាណិជ្ជកម្ម ឬការលើកផ្លាកយីហោ ឬប័ណ្ណប្រកាសផ្សាយដំណឹងផ្សេងៗ ដែលជាចំណូលសារពើពន្ធ និងស្ថិតក្រោមដែនសមត្ថកិច្ចប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ ។ ដោយឡែក សាលារាជធានីភ្នំពេញ គឺមានសមត្ថកិច្ចប្រមូលកម្រៃសេវាលើការអនុញ្ញាត និងការលើកផ្លាកយីហោ ឬប័ណ្ណប្រកាសផ្សាយដំណឹងផ្សេងៗ ដែលនេះគឺជាចំណូលមិនមែនសារពើពន្ធ ហើយក៏មិនមែនជាការយកពន្ធត្រួតគ្នានោះទេ។

អគ្គនាយកដ្ឋានពន្ធដារក៏បានជម្រាបអង្គប្រជុំថា អគ្គនាយកដ្ឋានពន្ធដារនឹងលើកសំណើនេះជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យសម្រេចលើករណីខាងលើនេះ ពោលគឺមិនបានលើកឡើងថា "**អគ្គនាយកដ្ឋានពន្ធដារ លែងអនុញ្ញាតឱ្យអាជ្ញាធរក្រុងភ្នំពេញប្រមូលពន្ធស្លាកយីហោនានា**" ដូចដែលសារព័ត៌មាន ឡារ៉ែន បានចុះផ្សាយនោះឡើយ ព្រោះថា អគ្គនាយកដ្ឋានពន្ធដារមិនមានសិទ្ធិក្នុងការលុបចោលការប្រមូលកម្រៃសេវាទាំងនេះរបស់សាលារាជធានីភ្នំពេញឡើយ។

អាស្រ័យហេតុនេះ សូមសាធារណជនមេត្តាជ្រាប និងស្នើសារព័ត៌មាន ឡារ៉ែន មេត្តាកែតម្រូវខ្លឹមសារនៃការចុះផ្សាយរបស់ខ្លួនឡើងវិញ។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧

**អគ្គនាយកដ្ឋានពន្ធដារ**